**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខៈ ០២១៥ ក.ស.ភ.

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំរកា ព.ស.២៥៦០

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា គ.ស.២០១៧

# សេចក្តីជូនដំណឹង

## ស្តីពីការបែងចែកភាគលាភរបស់ ក.ស.ភ. ប្រចាំឆ្នាំ២០១៦

**កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "**ក**" របស់ ក. ស. ភ. ឲ្យបានជ្រាបថា យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំជាវិសាមញ្ញលើកទី៥ អាណត្តិទី៦ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ **ក. ស. ភ.** បានសម្រេចបែងចែកភាគលាភប្រចាំឆ្នាំ២០១៦ ជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "**ក**" ដូចខាងក្រោម÷

១. ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend) : សាច់ប្រាក់

២. រយៈពេលភាគលាភ (Period of Dividend) : ប្រចាំឆ្នាំ ២០១៦

៣. អនុបាតនៃការបែងចែកភាគលាភ (Dividend Payout Ratio) : ៦,៣៩% ***

៤. ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend) : ១.០៥៩.០៣៩.៤៨៨ រៀល ***

៥. ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend per Share) : ២៥៦ រៀល ***

៦. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ (Record Date): **ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧**

៧. កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) : **ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧**

*** សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក"

ជាមួយគ្នានេះ ក. ស. ភ. សូមជម្រាបជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" ជ្រាបផងដែរថា ភាគលាភឆ្នាំ២០១៥ ដែលបានបង្គរទុក ចំនួន ១០៥.៩០៣.៩៤៩ រៀល (ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិចំនួន ២៥,៦០ រៀល និងអនុបាតសរុបដែលត្រូវបែងចែកចំនួន ០,៨២%) ក. ស. ភ. នឹងធ្វើការទូទាត់ជាមួយភាគលាភឆ្នាំ២០១៦។ ភាគហ៊ុនិក ដែលមានសិទ្ធិទទួលបានភាគលាភបង្គរឆ្នាំ២០១៥ គឺជាភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលប្រកាសយោងតាមកាលបរិច្ឆេទកំណត់ទុក **នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧**។



ទីស្នាក់ការកណ្តាលៈ អគារលេខ ៦៤៩ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh

បញ្ជាក់÷

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភតាមការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលទទួលបានពីបញ្ជីភាគហ៊ុនិកបណ្តោះអាសន្ន ដែលរៀបចំឡើង **នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧** ។
- ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន **នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧** នៅតែមានសិទ្ធិទទួលបានភាគលាភដដែល។
- ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិ **នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧** នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ។
- ការទូទាត់ភាគលាភជូនភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ នឹងចាប់ផ្តើមពី **ថ្ងៃទី២៩ ខែមីនា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧** នៅរៀងរាល់ថ្ងៃធ្វើការ។
- ភាគហ៊ុនិកអាចធ្វើការតវ៉ាលើការទូទាត់ភាគលាភចាប់ពី**ថ្ងៃទី៧ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧**។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ក.ស.ភ ដូចខាងក្រោម÷

- ឈ្មោះ : **ធនាគារ អេស៊ីលីដា ភីអិលស៊ី**
- អាសយដ្ឋាន : ជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះនរោត្តម សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ : + ៨៥៥ (0) ២៣ ៩៩៨ ៧៧៧ (Ext : ៨៣១៦៧)
- ទូរសារ : + ៨៥៥ (0) ២៣ ៩៩៨ ៦៦៦
- ទូរសព្ទដៃ : + ៨៥៥ (0) ១៥ ៦០០ ៧៨៣
- សារអេឡិចត្រូនិក : lim.an@acledabank.com.kh

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

PHNOM PENH AUTONOMOUS PORT

**ហ៊ី-បាវី**



ទីចាត់ការកណ្តាល: អគារលេខ ៦៤៩ តិរ:វិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh

ឈ្មោះក្រុមហ៊ុនបោះផ្សាយ: **កំពង់ផែស្វយ័តភ្នំពេញ**
អក្សរកូដរបស់ក្រុមហ៊ុនបោះផ្សាយ: KH1000040001
កាលបរិច្ឆេទនៃការបញ្ជូន:
ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ម៉ោង ១១ : ២៥នាទី

## ទម្រង់ទី ៩ : ការសម្រេចចិត្តបើកភាគលាភ

| | | |
|---|---|---|
| ១. ប្រភេទភាគលាភ | | ☐ ជាមូលបត្រកម្មសិទ្ធិ<br>☑ជាសាច់ប្រាក់<br>☐ ផ្សេងៗ : ........................................ |
| ២. រយៈពេលភាគលាភ | | ☑ ប្រចាំឆ្នាំ (២០១៥ និង២០១៦)<br>☐ ប្រចាំឆមាស<br>☐ ប្រចាំត្រីមាស<br>☐ ផ្សេងៗ : ........................................ |
| ៣. ភាគលាភក្នុងមួយ ឯកតាមូលបត្រកម្មសិទ្ធិ | មូលបត្រកម្មសិទ្ធិ (មានសិទ្ធិបោះឆ្នោត) | -សម្រាប់ឆ្នាំ ២០១៥ : ២៥,៦០ រៀល<br>-សម្រាប់ឆ្នាំ ២០១៦ : ២៥៦ រៀល |
| | ភាគហ៊ុនបុរិមា | គ្មាន |
| ៤. ភាគលាភសរុបដែលត្រូវបែងចែក | | -សម្រាប់ឆ្នាំ ២០១៥ : ២.២៥៥.៩០៣.៩៤៩ រៀល (ភាគហ៊ុនិកប្រភេទ “ក” និង “ខ”)<br>-សម្រាប់ឆ្នាំ ២០១៦ : ៣.២០៩.០៣៩.៤៨៨ រៀល (ភាគហ៊ុនិកប្រភេទ “ក” និង “ខ”) |
| ៥. កាលបរិច្ឆេទប្រកាសបើកភាគលាភ | | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ |
| ៦. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ | | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ |
| ៧. កាលបរិច្ឆេទទូទាត់ភាគលាភ | | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧ |
| ៨. ការសម្រេចចិត្តក្នុងការបើកភាគលាភ | ☐តាមរយៈមហាសន្និបាតភាគហ៊ុនិក | |
| | ☑តាមរយៈក្រុមប្រឹក្សាភិបាល | ចំនួនអភិបាលឯករាជ្យដែលចូលរួមៈ ១ នាក់ |
| ៩. កាលបរិច្ឆេទ និងពេលវេលានៃការសម្រេចចិត្ត | | ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ ម៉ោង ១០ : ៣០នាទី |
| ១០. ឯកសារភ្ជាប់ | | ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក. ស. ភ. ក្នុងកិច្ចប្រជុំជាវិសាមញ្ញលើកទី៥ អាណត្តិទី៦ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ |

ហត្ថលេខា និងឈ្មោះបុគ្គលិកទទួលបន្ទុក
ក្នុងការផ្តល់ព័ត៌មាន

ហ៊ឹ_ផានិន